**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ ថក ២៤/២០២៥ កបទ.សអ

# សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសេចក្តីរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយជាច្រើន ដកស្រង់សំដីរបស់ថ្នាក់ដឹកនាំថៃ ដែលបង្ហាញថាប្រទេសថៃបានផ្អាកការអនុវត្តនូវសេចក្តីថ្លែងការណ៍រួមរវាងនាយករដ្ឋមន្ត្រីកម្ពុជា និងថៃ ដែលត្រូវបានចុះហត្ថលេខា ដោយមានវត្តមានរបស់ឯកឧត្តម **ដូណាល់ ត្រាំ** ប្រធានាធិបតីសហរដ្ឋអាមេរិក និង ឯកឧត្តម **អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងជាប្រធានអាស៊ាន ធ្វើជាសាក្សី នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។

សេចក្តីរាយការណ៍ព័ត៌មានទាំងនេះក៏បានឱ្យដឹងដែរថា ព្រឹត្តិការណ៍ផ្ទុះមីននៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ ដែលបានធ្វើឱ្យទាហានថៃពីរនាក់រងរបួសនៅព្រំដែនកម្ពុជា-ថៃ ត្រង់តំបន់ភ្នំទ្រព្យ ស្ថិតជិតប្រាសាទព្រះវិហាររបស់កម្ពុជា ត្រូវបានលើកឡើងថាជាមូលហេតុនៃការផ្អាកអនុវត្តសេចក្តីថ្លែងការណ៍រួមខាងលើនេះ រួមទាំងការលុបចោលគម្រោងដោះលែងឃោជិនខ្មែរ ១៨រូប ពីការឃុំឃាំងនៅប្រទេសថៃ ដែលភាគីថៃបានប្រកាសថានឹងអនុវត្តនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥។

រាជរដ្ឋាភិបាលកម្ពុជាសូមបដិសេធយ៉ាងដាច់អហង្ការចំពោះរាល់ការចោទប្រកាន់របស់ប្រទេសថៃថាកម្ពុជាបានដាក់មីនថ្មីនៅតាមព្រំដែនជាមួយប្រទេសថៃ។ វាជាការសំខាន់ដែលត្រូវកត់សម្គាល់ពីការដឹងឮយ៉ាងសុះសាយនូវការពិតថា ចម្ការមីនភាគច្រើនតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដែលបន្សល់ទុកពីជំនាន់សង្គ្រាមស៊ីវិលកម្ពុជារយៈជិត៣០ឆ្នាំ ក្នុងទសវត្សរ៍ ១៩៧០ និង១៩៨០ មិនទាន់ត្រូវបានបោសសម្អាតនៅឡើយទេ ដោយសារតែភូមិសាស្ត្រលំបាក និងស្ថានភាពមិនទាន់មានការកំណត់ខណ្ឌសីមាព្រំដែន។

រាជរដ្ឋាភិបាលកម្ពុជាសូមបញ្ជាក់ជាថ្មីថា កម្ពុជានៅតែប្តេជ្ញាអនុវត្តសេចក្តីថ្លែងការណ៍រួម ដែលត្រូវបានចុះហត្ថលេខាជាមួយនិងការសាទរយ៉ាងខ្លាំងក្លាពីសហគមន៍អន្តរជាតិ។ ក្នុងនាមជាប្រទេសដែលបានគាំទ្រយ៉ាងមុតមាំ និងជារដ្ឋភាគីនៃអនុសញ្ញាហាមឃាត់មីនប្រឆាំងមនុស្ស កម្ពុជាមិនដែលបានប្រើប្រាស់ហើយក៏នឹងមិនប្រើប្រាស់មីនថ្មីឡើយ។

ថ្ងៃចន្ទ ៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២៥

អាសយដ្ឋានៈ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

*Unofficial Translation*

No. SM 24/2025 MFA.IC

# STATEMENT OF THE MINISTRY OF FOREIGN AFFAIRS AND INTERNATIONAL COOPERATION OF THE KINGDOM OF CAMBODIA

The Royal Government of Cambodia is gravely concerned about several media reports quoting statements by Thailand's leadership indicating that Thailand has suspended the implementation of the Joint Declaration between the Prime Ministers of Cambodia and Thailand, which was signed and witnessed by His Excellency Donald J. Trump, President of the United States, and His Excellency Anwar Ibrahim, Prime Minister of Malaysia and ASEAN Chair, in Kuala Lumpur, Malaysia, on 26 October 2025.

It is reported that a landmine explosion on 10 November 2025, injuring two Thai soldiers in the Cambodia-Thailand border area of Phnom Trop, which lies in the vicinity of the Temple of Preah Vihear of Cambodia has been cited as the reason for Thailand's suspending the implementation of the Joint Declaration, and also the cancellation of the announced release on 12 November 2025 of 18 Cambodian soldiers still in Thailand's detention.

The Royal Government of Cambodia categorically denies the allegations by Thailand that new landmines have been laid by Cambodia at the border with Thailand. It is important to note the well-known fact that most minefields, from nearly three decades of Cambodia's civil wars of the 1970s and 1980s, along the Cambodia-Thailand border have not yet been cleared due to difficult terrains and the un-demarcated status of the border areas.

The Royal Government of Cambodia wishes to affirm that Cambodia remains committed to implementing the Joint Declaration, which was signed amidst much applaud from the international community. Cambodia as a devoted advocate for and state party to the Anti-Personnel Mine Ban Convention has never used any new landmines and will never do so.

10 November 2025